# ចុល្លគន្ថវំសបាឡិ~ប្រែ

*រចនាដោយ*

## ព្រះនន្ទប្បញ្ញាថេរៈ

*ប្រែរៀបរៀងដោយ*

**ធម្មានន្ទ វ៉ាន់ ចាន់សារ៉ើន**

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*
*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*
*ព.ស.២៥៥៧*
*ឆ្នាំ ២០១៣*

# ចុល្លគន្ថវំសបាឡិ-ប្រែ

រចនាដោយ

**ព្រះនន្ទប្បញ្ញាថេរៈ**

ប្រែរៀបរៀងដោយ

**ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន**

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៧

---

ឆ្នាំ ២០១៣

| | |
|---|---|
| ឈ្មោះសៀវភៅ | ចុល្លគន្ថវំសបាឡិ-ប្រែ |
| រចនាដោយ | ព្រះនន្ទបញ្ញាថេរៈ |
| ប្រែរៀបរៀងដោយ | វ៉ាន់ ចាន់សាវ៉ែន |
| ត្រួតពិនិត្យជំនួយការ | លោក គង់ សំអឿន |
| ត្រួតពិនិត្យអក្ខរាវិរុទ្ធ | ឧបាសក ដាំ កុយ |
| ស្ថានទីធ្វើ | រាជធានីភ្នំពេញ |
| វាយអត្ថបទកុំព្យូទ័រ | វ៉ាន់ ចាន់សាវ៉ែន |
| បោះពុម្ពលើកទី ១ | សីហា ឆ្នាំ ២០០៥ |
| បោះពុម្ពលើកទី ២ | តុលា ឆ្នាំ ២០១៣ |

# សម្ពោធនីយកថា

គម្ពីរបុល្លគន្ថវិសេនេះរចនាឡើងដោយព្រះថេរៈនាម **នន្ទប្បញ្ញោ** ជនជាតិមន ។ ព្រះថេរៈអង្គនេះបានបព្វជ្ជានិងឧបសម្បទាក្នុងប្រទេសមនហើយមានបំណងសិក្សាព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ក៏បាននិមន្តមកក្រុងចៀងហ្មៃសិក្សាគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា ក្នុងសំណាក់ព្រះមហាថេរដែលនិមន្តមកពីប្រទេសស្រីលង្កា និងព្រះមហាថេរជនជាតិឡានណាច្រើនព្រះអង្គរហូតក្លាយជាអ្នកជំនាញក្នុងគម្ពីរព្រះត្រៃបិដក អដ្ឋកថា និងដីកា ។ កាលព្រះថេរៈសិក្សាគម្ពីរព្រះត្រៃបិដកជាដើមអស់ ២០ វស្សា ក៏នឿយណាយនឹងពួកគណៈបាននិមន្តទៅគង់នៅក្នុងព្រៃអស់ ៦ វស្សា ។ ក្នុងរវាង ៦ វស្សា ព្រះថេរៈក៏បានរចនានូវគម្ពីរបុល្លគន្ថវិសដ៏តូចនេះ សម្រាប់តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។

គម្ពីរបុល្លគន្ថវិសនេះបានរៀបរាប់ពីគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា យ៉ាងល្អ ជាពិសេសបានបញ្ជាក់ពីគម្ពីរនីមួយ ។ ដែលមានក្នុងព្រះពុទ្ធសាស-នា រចនាឡើងដោយព្រះថេរៈអង្គណា អ្នកណាជាអ្នកអារាធនា រចនាកាលណា គម្ពីរណាខ្លះលំដាប់ជាន់បិដក លំដាប់ជាន់អដ្ឋកថា លំដាប់ជាន់ដីកា តើការរចនាគម្ពីរមានអានិសង្សយ៉ាងណា ? ។

កាលខ្ញុំសិក្សាគម្ពីរបុល្លគន្ថវិសឃើញថា គម្ពីរបុល្លគន្ថវិសនេះមានសារសំខាន់បំផុតសម្រាប់អ្នកសិក្សាគម្ពីរព្រះពុទ្ធសាសនា គួរតែធ្វើជាបាលីមួយខាង សម្រាយមួយខាងតម្កល់ទុកក្នុងព្រះរាជាណាចក្រ កម្ពុជាតទៅ ។

ខ្ញុំសង្ឃឹមថា ព្រះថេរានុថេរៈគ្រប់ព្រះអង្គ លោកអ្នកសិក្សាទាំងអស់ បានទទួលអាននូវគម្ពីរនេះហើយ នឹងបានជាប្រទីបចង្អុលបំភ្លឺឲ្យបានស្គាល់នូវគម្ពីរព្រះពុទ្ធសាសនាកាន់តែខ្លាំងក្រៃលែងជាងមុន ។

**ចិរំ តិដ្ឋតុ សទ្ធម្មោ កាលេ វស្សំ ចិរំ បជំ**
**តប្បេតុ ទេវោ ធម្មេន រាជា រក្ខតុ មេទនី[១] ។**

*សូមព្រះសទ្ធម្មតាំងនៅអស់កាលដ៏យូរ សូមភ្លៀងបង្អុរមក*
*តាមរដូវកាល ដើម្បីញ៉ាំងសត្វឲ្យត្រេកអរ អស់កាលជា*
*អង្វែង សូមព្រះរាជាគ្រប់គ្រងផែនដីប្រកបដោយធម៌ ។*

*រាជធានីភ្នំពេញ*
*ថ្ងៃ សុក្រ ១៥ រោច ខែ អាសាឍ ឆ្នាំ រកា សប្តស័ក ព.ស.២៥៤៩*
*ត្រូវនឹងថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៥*

**ថ៊ាន់ ចាន់សារ៉ែន**

---

១ *សមន្តប្បាសាទិកាបាលី ភាគ ២ ទំព័រ ៦២៧ ។*

# មាតិកា


| លេខរៀង | មាតិកាអត្ថបទ | ទំព័រ |
|---|---|---|

១~សម្មោទនីយកថា........................................................ ក

២~បរិច្ឆេទនិយាយពីព្រះត្រៃបិដក.................................... ១

៣~បរិច្ឆេទរៀបរាប់អាចារ្យអ្នករចនាគម្ពីរ......................... ៦

៤~បរិច្ឆេទរៀបរាប់ទីកំណើតរបស់អាចារ្យ........................ ១៣

៥~គម្ពីររចនាដោយមានអ្នកអារាធនាជាដើម................. ១៥

៦~គម្ពីរព្រះពុទ្ឋឃោសាចារ្យរចនា................................... ១៥

៧~គម្ពីរព្រះពុទ្ធទត្តាចារ្យរចនា......................................... ១៧

៨~គម្ពីព្រះធម្មបាលាចារ្យរចនា....................................... ១៧

៩~គម្ពីរអាចារ្យផ្សេង ៗ រចនា......................................... ១៨

១០~បកិណ្ណកៈរាយរង......................................................... ២៥

១១~ការសរសេរព្រះពុទ្ធវចនៈឡើងកាន់ស្លឹករឹត.............. ២៦~២៧

១២~អានិសង្សប្រចារគម្ពីរព្រះត្រៃបិដក............................. ៣០

១៣~និគមនកថាអ្នករចនាគម្ពីរ....................................... ៣៣

# ចុល្លគន្ថវំសបាឡិ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

**បិដកត្តយបរិច្ឆេទោ**

នមស្សេត្វាន សម្ពុទ្ធំ អគ្គំវិសវំវំវំ
នត្វាន ធម្មំ ពុទ្ធជំ សង្ឃញ្ចាបិនិរង្គណំ ។
គន្ថវំសម្បិ និស្សាយ គន្ថវំសំ បកថិស្សំ
តិបេដកសមាហារំ សាធុនំ ជង្ឃទាសកំ ។
វិមតិនោទនមារម្ភំ តំ មេ សុណាថ សាធវោ
សព្វម្បិ ពុទ្ធវចនំ វិមុត្តិ ច សហេតុកំ
ហោតិ ឯកវិធំយេវ តិវិធំ បិដកេន ច
តញ្ច សព្វម្បិ កេវលំ បញ្ចវិធំ និកាយតោ
អង្គតា ច នវវិធំ ធម្មក្ខន្ធគណនតោ
ចតុរាសីតិ សហស្ស- ធម្មក្ខន្ធបភេទនន្តិ ។

កថំ បិដកតោ បិដកញ្ហិ តិវិធំ ហោតិ ? វិនយបិដកំ អភិធម្មបិដកំ សុត្តន្តបិដកន្តិ ។ តត្ថ កតមំ វិនយបិដកំ ? បារាជិកកណ្ឌំ

# ចុល្លគន្ថវំសប្រែ

សូមថ្វាយបង្គំព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ

**១.បរិច្ឆេទនិយាយអំពីព្រះត្រៃបិដក**

ខ្ញុំព្រះករុណាសូមថ្វាយបង្គំព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ទ្រង់ជាអគ្គបុគ្គលនិងមានវង្សដ៏ល្អ សូមថ្វាយបង្គំចំពោះព្រះធម៌ដែលកើតអំពីព្រះពុទ្ធអង្គ និងថ្វាយបង្គំព្រះសង្ឃឥតមានទីទួលគឺកិលេស ។ ខ្ញុំអាស្រ័យគន្ថវំស[១]ហើយ នឹងពណ៌នាគន្ថវំសជាទីរួបរួមព្រះត្រៃបិដក ស៊ូជាខ្ញុំបម្រើជើងនៃសាធុសប្បុរសទាំងឡាយ ។ ហៃសាធុសប្បុរសទាំងឡាយសូមស្តាប់នូវគន្ថវំសរបស់ខ្ញុំ ជាហេតុព្យាយាមបន្ទោបង់នូវសេចក្តីសង្ស័យ ព្រះពុទ្ធវចនៈទាំងអស់មានតែមួយគឺវិមុត្តិជាសហេតុកៈ មាន ៣ រាប់តាមបិដក មាន ៥ រាប់តាមនិកាយ មាន ៩ រាប់តាមអង្គ មាន ៨៤០០០ រាប់តាមធម្មក្ខន្ធ ។

បិដកមាន ៣ តើដូចម្តេចខ្លះ ? ។ គឺវិនយបិដក ១ អភិធម្មបិដក ១ សុត្តន្តបិដក ១ ។ បណ្តាបិដកទាំង ៣ នោះ វិនយបិដក តើដូចម្តេចខ្លះ? ។

[១] ១ គម្ពីរគន្ថវំសដែលលោកអាងក្នុងទីនេះ សំដៅដល់ គម្ពីរមហាវំសខ្លះ អដ្ឋកថាខ្លះ ។

បាចិត្តិយកណ្ឌំ មហាវគ្គកណ្ឌំ ចុល្លវគ្គកណ្ឌំ បរិវារកណ្ឌន្តិ ។ ឥមានិ កណ្ឌានិ វិនយបិដកំ នាម ។

កតមំ អភិធម្មបិដកំ ? ។ ធម្មសង្គណិប្បករណំ វិភង្គប្បករណំ ធាតុកថាបករណំ បុគ្គលបញ្ញត្តិប្បករណំ កថាវត្ថុប្បករណំ យមកប្បករណំ បដ្ឋានប្បករណន្តិ ។ ឥមានិ សត្ត បករណានិ អភិធម្មបិដកំ នាម ។ កតមំ សុត្តន្តបិដកំ ?។សីលក្ខន្ធវគ្គាទិកំ, អវសេសំ ពុទ្ធវចនំ សុត្តន្តបិដកំ នាម ។

កថំ និកាយតោ ?។ និកាយា បញ្ច វិធា ហោន្តិ ទីឃនិកាយោ មជ្ឈិមនិកាយោ សំយុត្តនិកាយោ អង្គុត្តរនិកាយោ ខុទ្ទកនិកាយោតិ ។

តត្ថ កតមោ ទីឃនិកាយោ ?។ សីលក្ខន្ធវគ្គោ មហាវគ្គោ បាដិកវគ្គោតិ ឥមេ តយោ វគ្គា ទីឃនិកាយោ នាម ។ ឥមេសុ តីសុ វគ្គេសុ ចតុតឹស វគ្គានិ ច ហោន្តិ ។ ចតុតឹសេវ សុត្តន្តា, សីលក្ខន្ធវគ្គាទិកា, យស្ស ភវន្តិ សោ យេវ ទីឃនិកាយ នាម ហោតិ ។

កតមោ មជ្ឈិមនិកាយោ ?។ មូលបណ្ណាសោ មជ្ឈិមបណ្ណាសោ ឧបរិបណ្ណាសោតិ ឥមេ តយោ បណ្ណាសា មជ្ឈិមនិកាយោ នាម ។ ឥមេសុ តីសុ បណ្ណាសេសុ ទ្វេបញ្ញាសាធិកសុត្តសតានិ ហោន្តិ ។ ទិយឌ្ឍសតសុត្តន្តា ទ្វិ សុត្តំ យស្ស សន្តិសោ, មជ្ឈិមនិកាយោ នាមោ មូលបណ្ណាសមាទិ ហោតិ ។

កតមោ សំយុត្តនិកាយោ ?។ សគាថាវគ្គោ និទានវគ្គោ ខន្ធកវគ្គោ សឡាយតនវគ្គោ មហាវគ្គោតិ ឥមេ បញ្ច វគ្គា សំយុត្តនិកាយោ នាម ។

គឺបារាជិកកណ្ឌ ១ បាចិត្តិយកណ្ឌ ១ មហាវគ្គកណ្ឌ១ ចុល្លវគ្គកណ្ឌ ១ បរិវារកណ្ឌ ១ ។ កណ្ឌទាំងនេះ ឈ្មោះថា វិនយបិដក ។ អភិធម្មបិដក តើដូចម្ដេចខ្លះ? ។ គឺធម្មសង្គណិប្បករណ៍ ១ វិភង្គប្បករណ៍ ១ ធាតុកថា-បករណ៍ ១ បុគ្គលប្បញ្ញត្តិប្បករណ៍ ១ កថាវត្ថុប្បករណ៍ ១ យមកប្បករណ៍១ បដ្ឋានប្បករណ៍ ១ ។ បករណ៍ទាំង ៧ នេះ ឈ្មោះថា អភិធម្មបិដក ។ សុត្តន្តបិដក តើដូចម្ដេចខ្លះ? ។ ព្រះពុទ្ធវចនៈដ៏សេសមានសីលក្ខន្ធវគ្គជាដើម ឈ្មោះថា សុត្តន្តបិដក ។

និកាយ តើដូចម្ដេចខ្លះ ? ។ និកាយមាន ៥ គឺទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

បណ្ដានិកាយទាំង ៥ នោះ ទីឃនិកាយ ដូចម្ដេចខ្លះ? ។ សីលក្ខន្ធវគ្គ១ មហាវគ្គ ១ បាដិកវគ្គ ១ រួមវគ្គទាំង ៣ នេះ ឈ្មោះថា ទីឃនិកាយ ។ ក្នុងវគ្គទាំង ៣ នេះ មានសូត្រ ៣៤ ។ និកាយណាមានសូត្រ ៣៤ មាន សីលក្ខន្ធវគ្គជាដើម និកាយនោះឯង ឈ្មោះថា ទីឃនិកាយ ។

មជ្ឈិមនិកាយដូចម្ដេចខ្លះ ? ។ មូលបណ្ណាសៈ ១ មជ្ឈិមបណ្ណាសៈ ១ ឧបរិបណ្ណាសៈ ១ រួមបណ្ណាសៈទាំង ៣ នេះ ឈ្មោះថា មជ្ឈិមនិកាយ ។ ក្នុងបណ្ណាសៈទាំង ៣ នេះ មានសូត្រ ១៥២ ។ និកាយណាមានសូត្រ ១៥២ មានមូលបណ្ណាសៈជាដើម និកាយនោះឯង ឈ្មោះថា មជ្ឈិមនិកាយ ។

សំយុត្តនិកាយ ដូចម្ដេចខ្លះ? ។ សគាថាវគ្គ ១ និទានវគ្គ ១ ខន្ធកវគ្គ ១ សឡាយតនវគ្គ ១ មហាវគ្គ ១ រួមវគ្គទាំង ៥ នេះ ឈ្មោះថា សំយុត្តនិកាយ។

ឥមេសុ បញ្ចសុ វគ្គេសុ ទ្វាសដ្ឋិសុត្តសត្តសតាធិកសត្តសុត្តសហស្សានិ ហោន្តិ ។ ទ្វាសដ្ឋិសត្តសតានិ សត្តសហស្សកានិ ច ។ សុត្តានិ យស្ស ហោន្តិ សោ, សគាថាទិកវគ្គកោ សំយុត្តនិកាយោ នាមោ វេទិតព្វោ ច វិញ្ញូនាតិ ។

កតមោ អង្គុត្តរនិកាយោ ?។ ឯកនិបាតោ ទុក្កនិបាតោ តិក្កនិបាតោ ចតុក្កនិបាតោ បញ្ចកនិបាតោ ឆក្កនិបាតោ សត្តកនិបាតោ អដ្ឋកនិបាតោ នវកនិបាតោ ទសកនិបាតោ ឯកាទសនិបាតោតិ, ឥមេ ឯកាទស និបាតា អង្គុត្តរនិកាយោ នាម ។ ឥមេសុ ឯកាទស និបាតេសុ សត្តបញ្ញាស-បញ្ចសតាធិកនវសុត្តសហស្សានិ ហោន្តិ ។ នវសុត្តសហស្សានិ បញ្ចសត-មត្តានិ ច, សត្តបញ្ញាសាធិកានិ សុត្តានិ យស្ស ហោន្តិ សោ, អង្គុត្តរនិកាយោតិ ឯកនិបាតកាទិកោតិ ។

កតមោ ខុទ្ទកនិកាយោ ?។ ខុទ្ទកបាឋោ ធម្មបទំ ឧទានំ ឥតិវុត្តកំ សុត្តនិបាតោ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតកំ មហា-និទ្ទេសោ បដិសម្ភិទាមគ្គោ អបទានំ ពុទ្ធវំសោ ចរិយាបិដកំ វិនយបិដកំ អភិធម្មបិដកន្តិ ។ ឥមេសុ សត្តរសសុ គន្ថេសុ អនេកានិ សុត្ត-សហស្សានិ ហោន្តិ ។ (អនេកានិ សុត្តសហស្សានិ, និទ្ទិដ្ឋានិ មហេសិនា, និកាយេ បញ្ចមេ ឥមេ ខុទ្ទកេ ឥតិ វិសុតេតិ ) ។

កថំ អង្គតោ អង្គេហិ នវ វិធំ ហោតិ ? សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវប្បភេទំ ហោតិ ។ តត្ថ ឧភតោ វិភង្គនិទ្ទេសខន្ធកបរិវារា, សុត្តនិបាតេ

ក្នុងវគ្គទាំង ៥ នេះ មានសូត្រ ៧៧៦២ ។ និកាយណាមានសូត្រ ៧៧៦២ មានសគាថាវគ្គជាដើម និកាយនោះ វិញ្ញូជនគប្បីជ្រាបថា សំយុត្តនិកាយ ។

អង្គុត្តរនិកាយ តើដូចម្ដេចខ្លះ? ។ ឯកនិបាត ១ ទុកនិបាត ១ តិកនិបាត ១ ចតុក្កនិបាត ១ បញ្ចកនិបាត ១ ឆក្កនិបាត ១ សត្តកនិបាត ១ អដ្ឋកនិបាត ១ នវកនិបាត ១ ទសកនិបាត ១ ឯកាទសកនិបាត ១ រួមនិបាតទាំង ១១ នេះ ឈ្មោះថា អង្គុត្តរនិកាយ ។ ក្នុងនិបាតទាំង ១១ នេះ មានសូត្រ ៩៥៥៧ ។ និកាយណាមានសូត្រ ៩៥៥៧ មានឯកនិបាតជាដើម និកាយនោះឯង ឈ្មោះថាអង្គុត្តរនិកាយ ។

ខុទ្ទកនិកាយ ដូចម្ដេចខ្លះ? ។ ខុទ្ទកបាឋៈ ១ ធម្មបទ ១ ឧទាន ១ ឥតិវុត្តកៈ ១ សុត្តនិបាត ១ វិមានវត្ថុ ១ បេតវត្ថុ ១ ថេរគាថា ១ ថេរីគាថា ១ ជាតក ១ មហានិទ្ទេស ១ បដិសម្ភិទាមគ្គ ១ អបទាន ១ ពុទ្ធវំសៈ ១ ចរិយាបិដក ១ វិនយបិដក ១ អភិធម្មបិដក ១ ។ ក្នុងគន្ថៈទាំង ១៧ នេះ (ឈ្មោះថា ខុទ្ទកនិកាយ ) មានសូត្រច្រើនពាន់ជាអនេក ។ (ព្រះសម្ពុទ្ធព្រះអង្គទ្រង់ស្វែងរកគុណធំបានសម្ដែង ខុទ្ទកនិកាយទី ៥ នេះ ផ្សព្វផ្សាយទៅមានព្រះសូត្រច្រើនពាន់ជាអនេក ដូច្នេះឯង ) ។

ពុទ្ធវចនៈមាន ៩ រាប់តាមអង្គ ដូចម្ដេចខ្លះ ? ។ គឺ សុត្តៈ១ គេយ្យៈ១ វេយ្យាករណៈ១ គាថា ១ ឧទាន ១ ឥតិវុត្តកៈ ១ ជាតក ១ អព្ភូតធម្មៈ១ វេទល្លៈ ១ ។ បណ្ដាអង្គទាំង ៩ នោះ ឧភតោវិភង្គនិទ្ទេស ខន្ធកៈ បរិវារៈ និង

មង្គលសុត្តរតនសុត្តតុវដ្តកសុត្តានិ ។ អញ្ញម្បិ សុត្តនាមកំ តថាគតវចនំ, សុត្តន្តិ វេទិតព្វំ ។ សព្វំ សគាថកំ គេយ្យន្តិ វេទិតព្វំ ។ វិសេសន-សំយុត្តកេ សកលោបិ សគាថកវគ្គោ, សកលំ អភិធម្មបិដកំ និគាថកញ្ច សុត្តយញ្ច អញ្ញម្បិ អដ្ឋហិ អង្គេហិ អសង្គហិតំ ពុទ្ធវចនំ តំ វេយ្យាករណន្តិ វេទិតព្វំ ។ ធម្មបទំ ថេរគាថា ថេរីគាថា សុត្តនិបាតេ, នោ សុត្តនាមិកា សុទ្ធិកគាថា, គាថាតិ វេទិតព្វា ។ សោមនស្សញ្ញាណមយិកគាថា បដិកសំយុត្តា ទ្វេ អសីតិសុត្តន្តា ឧទានន្តិ វេទិតព្វា ។ វុត្តញ្ហេតំ ភគវតាតិអាទិនយប្បវត្តា ទសុត្តរសតសុត្តន្តា, ឥតិវុត្តកន្តិ វេទិតព្វា ។ អបណ្ណកជាតកាទីនិ បញ្ញាសាធិកានិ បញ្ចជាតកសតានិ ជាតកន្តិ វេទិតព្វំ ។ ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា, អានន្ទេតិ-អាទិនយប្បវត្តា សព្វេបិ អច្ឆរិយាព្ភុតធម្មបដិសំយុត្តា សុត្តន្តា អព្ភុតធម្មន្តិ វេទិតព្វា ។ ចុល្លវេទល្លមហាវេទល្លសម្មាទិដ្ឋិសក្កបញ្ហសង្ខារភាជនិយមហា-បុណ្ណមសុត្តន្តាទយោ សព្វេបិ វេទញ្ច តុដ្ឋិញ្ច លទ្ធា (បុច្ឆ) លទ្ធា បុច្ឆិតសុត្តន្តា, វេទល្លន្តិ វេទិតព្វា ។ កតមានិ ចតុរាសីតិ ធម្មក្ខន្ធ-សហស្សានិ ទុជានានិ, ចតុរាសីតិ ធម្មក្ខន្ធសហស្សានិ សចេ វិត្ថារេន កថិស្សំ អតិបបញ្ចោ ភវិស្សតិ ។ តស្មា នយវសេន កថិស្សាមិ ។ ឯកំ វត្ថុ ឯកោ ធម្មក្ខន្ធោ, ឯកំ និទានំ ឯកោ ធម្មក្ខន្ធោ, ឯកំ បញ្ហា បុច្ឆន្តំ

មង្គលសូត្រ រតនសូត្រ តុវដ្តកសូត្រ ក្នុងសុត្តនិបាត បណ្ឌិតគប្បីជ្រាបថា សុត្ត: ។ម្យ៉ាងទៀត សូត្រដទៃដែលជាពាក្យតថាគត ដែលមានឈ្មោះថា សូត្រ បណ្ឌិតគប្បីជ្រាបថា សុត្ត: ដែរ ។ ពុទ្ធវចនៈទាំងអស់ដែលមានគាថា បណ្ឌិតគប្បីជ្រាបថា គេយ្យ: ។ សគាថាវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ដោយវិសេស អភិធម្មបិដកទាំងអស់ សូត្រមិនមានគាថានិងពុទ្ធវចនៈដទៃ មិនសង្គ្រោះចូលក្នុងអង្គ ៨ នោះ បណ្ឌិតគប្បីជ្រាបថា វេយ្យាករណ: ។ ធម្មបទ ថេរគាថា ថេរីគាថា ក្នុងសុត្តនិបាត និងគាថាសុទ្ធដែលមិនមែនជាសូត្រ បណ្ឌិតគប្បីជ្រាបថា គាថា ។ សូត្រ ៨២ ដែលប្រកបដោយសោមនស្សញាណគាថា បណ្ឌិតគប្បីជ្រាបថា ឧទាន ។ សូត្រ១១០ មានន័យជាអាទិថា វុត្តញ្ហេតំ គប្បីជ្រាបថា ឥតិវុត្តក: ។ ជាតក៥៥០មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតក ។ ព្រះសូត្របដិសំយុត្តដោយអច្ឆរិយាភូតធម៌ សូម្បីទាំងអស់ដែលមានន័យជាអាទិថា ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ បណ្ឌិតគប្បីជ្រាបថា អព្ភូតធម្ម: ។ ចុល្លវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនិយសូត្រ ព្រះសូត្រដែលមនុស្សជាដើមសួរ ហើយបានសេចក្ដីដឹងនិងសេចក្ដីត្រេកអរ សូម្បីទាំងអស់មានមហាបុណ្ណមសូត្រជាដើម បណ្ឌិតគប្បីជ្រាបថា វេទល្ល: ។ ពុទ្ធវចនៈ ៨៤០០០ ធម្មក្ខន្ធ ដែលគេដឹងបានដោយកម្រ ដូចម្ដេចខ្លះ? បើខ្ញុំពណ៌នាពុទ្ធវចនៈ ៨៤០០០ ធម្មក្ខន្ធ ដោយពិស្ដារ នឹងមានការវែងណាស់ ។ ព្រោះដូច្នោះ ខ្ញុំនឹងពណ៌នាតែន័យ ។ រឿងមួយ ជាធម្មក្ខន្ធ ១ និទានមួយ

ឯកោ ធម្មក្ខន្ធោ, ឯកំ បញ្ហាវិសជ្ជនំ ឯកោ ធម្មក្ខន្ធោ, ចតុរាសីតិ ធម្មក្ខន្ធសហស្សានិ កេន ភាសិតានិ, កត្ថ ភាសិតានិ, កទា ភាសិតានិ, កមារព្ភ ភាសិតានិ, កិមត្ថំ ភាសិតានិ, កេន ធារិតានិ, កេនាភតានិ, កិមត្ថំ បរិយាបុណិតព្វានិ ។ តត្រាយំ វិសជ្ជនា, កេន ភាសិតានីតិ ? ពុទ្ធានុពុទ្ធេហិ ភាសិតានិ ។ កត្ថ ភាសិតានីតិ ? ទេវេសុ ច មានុស្សេសុ ច, ភាសិតានិ ។ កទា ភាសិតានីតិ ? ភគវតោ ធរមានកាលេ ចេវ បច្ឆិមកាលេ ច ភាសិតានិ ។ កតមារព្ភ ភាសិតានីតិ ? បញ្ចវគ្គិយាទិកេ វេនេយ្យពន្ធវេ អារព្ភ ភាសិតានីតិ ។ កិមត្ថំ ភាសិតានីតិ ?។ តិវជ្ជញ្ច អវជ្ជញ្ច ញត្វា វជ្ជំ បហាយ អវជ្ជេ បដិបត្តិត្វា និព្វានបរិយន្តេ ទិដ្ឋ-ធម្មិកសម្បរាយិកត្ថេ សម្បាបុណិតុំ ។

កេន ធារិតានីតិ ?។ អនុពុទ្ធេហិ ចេវ សិស្សានុសិស្សេហិ ច ធារិតានិ ។ កេនា ភតានីតិ ? អាចរិយបរម្បរេហិ អាភតានិ ។ កិមត្ថំ បរិយាបុណិតព្វានីតិ ? វជ្ជញ្ច អវជ្ជញ្ច ញត្វា វជ្ជំ បហាយ អវជ្ជេ បដិបត្តិត្វា និព្វានបរិយន្តេ ទិដ្ឋធម្មិកសម្បរាយិកត្ថេ, សម្បាបុណិតុំ, យទេវំ តាយ និព្វានបរិយន្តេ ទិដ្ឋធម្មិកសម្បរាយិកត្ថេ សាធិកានិ ហោន្តិ ។ តេវ តត្ថ កេហិ អប្បមត្តេន បរិយាបុណិតព្វានិ ធារេតព្វានិ វាចេតព្វានិ សជ្ឈាយំ កាតព្វានីតិ ។ (ឥតិ ចុល្លគន្ថវំសេ បិដកត្តយទីបកោ នាម បឋមោ បរិច្ឆេទោ) ។

ជាធម្មក្ខន្ធ ១ សួរបញ្ហាមួយ ជាធម្មក្ខន្ធ ១ វិសជ្ជនាមួយ ជាធម្មក្ខន្ធ ១ ពុទ្ធវចនៈ ៨៤០០០ ធម្មក្ខន្ធ អ្នកណាសម្តែង សម្តែងក្នុងទីណា សម្តែងក្នុងកាលណា សម្តែងប្រារព្ធអ្នកណា សម្តែងដើម្បីអ្វី អ្នកណាទ្រទ្រង់ទុក អ្នកណានាំមក បុគ្គលរៀនដើម្បីអ្វី ។ ក្នុងប្រស្នានោះ មានវិសជ្ជនាដូចតទៅនេះ÷ ត្រង់សំនួរថា អ្នកណាសម្តែង ។ ឆ្លើយថា ព្រះពុទ្ធនិងអនុពុទ្ធទាំងឡាយសម្តែង ។ សម្តែងក្នុងទីណា ។ ក្នុងទេវលោកនិងមនុស្សលោក ។ សម្តែងក្នុងកាលណា ។ កាលព្រះមានព្រះភាគគង់ធរមាននៅនិងបច្ឆិមកាល ។ សម្តែងប្រារព្ធអ្នកណា ។ ប្រារព្ធសត្វអ្នកមានវេនេយ្យគួរដឹកនាំបាន មានបញ្ចវគ្គិយភិក្ខុជាដើម ។ សម្តែងដើម្បីអ្វី ។ ដើម្បីដឹងធម៌មានទោសនិងធម៌មិនមានទោស លះបង់ធម៌មានទោស បដិបត្តិធម៌មិនមានទោស ហើយសម្រេចប្រយោជន៍បច្ចុប្បន្ននិងបរលោក មាននិព្វានជាទីបំផុត ។ អ្នកណាទ្រទ្រង់ទុក ។ អនុពុទ្ធនិងសិស្សានុសិស្សទាំងឡាយ ទ្រទ្រង់ទុក ។ អ្នកណានាំមក ។ បរម្បរាចារ្យនាំមក ។ គប្បីរៀនដើម្បីអ្វី ។ ដើម្បីដឹងធម៌មានទោសនិងធម៌មិនមានទោស លះបង់ធម៌មានទោស បដិបត្តិធម៌ មិនមានទោស ហើយសម្រេចប្រយោជន៍បច្ចុប្បន្ននិងបរលោក មាននិព្វានជាទីបំផុត ។ ពុទ្ធវចនៈ៨៤០០០ ធម្មក្ខន្ធ រមែងញុំាងប្រយោជន៍បច្ចុប្បន្ននិងបរលោក មាននិព្វានជាទីបំផុតឲ្យសម្រេច ដោយប្រការយ៉ាងនេះ ។ មែនពិត ជនដែលរៀនទ្រទ្រង់ចាំ បង្រៀន ធ្វើការស្វាធ្យាយក្នុងពុទ្ធវចនៈនោះ មានចំនួនតិចនាក់ ។

*(បរិច្ឆេទទី១រៀបរាប់ព្រះត្រៃបិដកក្នុងចុល្លគន្ថវិសចប់តែប៉ុណ្ណេះ)* ។

## ២.គន្ថការកាចរិយបរិច្ឆេទោ

អាចរិយោ បន អត្ថិ ។ បោរាណាចរិយា អត្ថិ, អដ្ឋកថាចរិយា អត្ថិ, គន្ថការកាចរិយា អត្ថិ, តិវិធនាមិកាចរិយា ។ កតមេ បោរាណាចរិយា ?។ បឋមសង្គាយនាយំ បញ្ចសតា ខីណាសវា បញ្ចន្នំ និកាយានំ នាមញ្ច អត្ថញ្ច អធិប្បាយញ្ច យទញ្ច ព្យញ្ជនសោធនញ្ច អវសេសំ កិច្ចំ ករឹសុ ។ ទុតិយសង្គាយនាយំ សត្តសតា ខីណាសវា តេសំយេវ សទ្ទត្ថាទិកំ កិច្ចំ បុន ករឹសុ ។ តតិយសង្គាយនាយំ សហស្សមត្តា ខីណាសវា តេសំយេវ សទ្ទត្ថាទិកំ កិច្ចំ បុន ករឹសុ ។ ឥច្ចេវំ ទ្វេសតាធិកា ទ្វេសហស្ស ខីណាសវា មហាកច្ចាយនំ ឋបេត្វា អវសេសា បោរាណាចរិយា នាម ។ យេ បោរាណាចរិយា តេយេវ អដ្ឋកថាចរិយា នាម ។ កតមេ គន្ថការកាចរិយា ?។ មហាអដ្ឋកថិកាបភេទអនេកាចរិយា គន្ថការកាចរិយា នាម ។ កតមេ តិវិធ នាមាចរិយា មហាកច្ចាយនោ តិវិធនាមំ ។ កតមេ គន្ថា មហាកច្ចាយនេន កតា ?។ កច្ចាយនគន្ថោ មហានិរុត្តិគន្ថោ ចុល្លនិរុត្តិគន្ថោ យមកគន្ថោ នេត្តិគន្ថោ បេដកោបទេសគន្ថោតិ ឥមេ ឆ គន្ថា មហាកច្ចាយនេន កតា ។ កតមេ អនេកាចរិយេន កតា គន្ថា ?។ មហាបច្ចរិកាចរិយោ មហាបច្ចរិយំ នាម គន្ថំ អកាសិ ។ មហាកុរុន្ទិកា_ចរិយោ កុរុន្ទិ នាម គន្ថំ អកាសិ ។ អញ្ញតរោ អាចរិយោ មហាបច្ចរិយ_គន្ថស្ស អដ្ឋកថំ អកាសិ ។ អញ្ញតរោ អាចរិយោ កុរុន្ទិគន្ថស្ស អដ្ឋកថំ

## ២.បរិច្ឆេទរៀបរាប់អាចារ្យអ្នករចនាគម្ពីរ

ចុះអាចារ្យមានប៉ុន្មាន ។ អាចារ្យមាន៣ គឺ បោរាណាចារ្យ ១ អដ្ឋកថាចារ្យ ១ គន្ថការកាចារ្យ ១ ។ បោរាណាចារ្យ តើដូចម្ដេច ? ។ ព្រះខីណាស្រព ៥០០ អង្គ ក្នុងបឋមសង្គាយនាបានធ្វើនាម អត្ថ អធិប្បាយ និងកិច្ចជម្រះព្យញ្ជនៈនិកាយទាំង ៥ មិនឲ្យសេសសល់ ។ ក្នុងទុតិយសង្គាយនា (សង្គាយនាទី ២ ) ព្រះខីណាស្រព ៧០០ អង្គ បានធ្វើកិច្ចមានអត្ថនៃសព្ទ ជាដើមរបស់និកាយទាំង ៥ នោះទៀត ។ ក្នុងតតិយសង្គាយនា ព្រះខីណា~ស្រព ១០០០ អង្គ បានធ្វើកិច្ចមានអត្ថនៃសព្ទជាដើម របស់និកាយទាំង ៥ នោះទៀត ។ ព្រះខីណាស្រព ២២០០ អង្គដូចពោលមកនេះ វៀរលែងតែព្រះមហាកច្ចាយនៈចេញ ឈ្មោះថា បោរាណាចារ្យ ។ បោរាណាចារ្យទាំងនោះឯង ឈ្មោះថា អដ្ឋកថាចារ្យ ។ គន្ថការកាចារ្យ ដូចម្ដេច ? ។ មហា~អដ្ឋកថាចារ្យច្រើនប្រភេទជាអនេក ឈ្មោះថា គន្ថការកាចារ្យ ។ អាចារ្យណាមានឈ្មោះ ៣ ។ ព្រះមហាកច្ចាយនៈមានឈ្មោះ ៣[1] ។ ព្រះមហា~កច្ចាយនៈបានរចនាគម្ពីរអ្វីខ្លះ? ។ ព្រះមហាកច្ចាយនៈ បានរចនាគម្ពីរ ៦ គឺ គម្ពីរកច្ចាយនៈ[2]១ មហានិរុត្តិ ១ ចុល្លនិរុត្តិ ១ យមកៈ ១ នេត្តិ[3] ១ បេដកោបទេស[4] ១ ។ អនេកាចារ្យ ( អាចារ្យច្រើន ) បានរចនាគម្ពីរអ្វីខ្លះ? ។ មហាបច្ចរិកាចារ្យបានរចនាគម្ពីរឈ្មោះ មហាបច្ចរិយ ។ មហាកុរុន្ទិកាចារ្យ

---

១បោរាណាចារ្យ ១ អដ្ឋកថាចារ្យ ១ គន្ថការកាចារ្យ ១ ។ ២ គឺគម្ពីរកច្ចាយនព្យាករណ៍ ។ ៣ នេត្តិប្បករណ៍ ៤ បេដកោបទេសប្បករណ៍ ។

អកាសិ ។ មហាពុទ្ធឃោសា នាមចរិយោ វិសុទ្ធិមគ្គោ, ទីឃនិកាយស្ស សុមង្គលវិលាសនិ នាម អដ្ឋកថា, មជ្ឈិមនិកាយស្ស បបញ្ចសូទនី នាម អដ្ឋកថា, សំយុត្តនិកាយស្ស សារត្ថប្បកាសិនី នាម អដ្ឋកថា, អង្គុត្តរ-និកាយស្ស មនោរថបូរណី នាម អដ្ឋកថា, បញ្ចវិនយគន្ថានំ សមន្តប្បា-សាទិកា នាម អដ្ឋកថា, សត្តន្នំ អភិធម្មគន្ថានំ បរមត្ថកថា នាម អដ្ឋកថា, បាតិមោក្ខសំខាតាយ មាតិកាយ កង្ខាវិតរណីតិ វិសុទ្ធិ នាម អដ្ឋកថា, ធម្មបទស្ស អដ្ឋកថា, ជាតកស្ស អដ្ឋកថា, ខុទ្ទកបាឋស្ស អដ្ឋកថា, សុត្តនិបាតស្ស អដ្ឋកថា, អបទានស្ស អដ្ឋកថាតិ ឥមេ តេរស គន្ថេ អកាសិ ។ ពុទ្ធទត្តោ នាមាចរិយោ វិនយវិនិច្ឆយោ ឧត្តរវិនិច្ឆយោ អភិធម្មាវតារោ ពុទ្ធវំសស្ស មធុរត្ថវិលាសិនី នាម អដ្ឋកថាតិ ឥមេ ចត្តារោ គន្ថេ អកាសិ ។ អានន្ទោ នាមាចរិយោ សត្តាភិធម្មគន្ថដ្ឋកថាយ មូលដីកំ នាម ដីកំ អកាសិ ។ ធម្មបាលាចរិយោ នេត្តិប្បករណដ្ឋកថា, ឥតិវុត្តកដ្ឋកថា, ឧទានដ្ឋកថា, ចរិយាបិដកដ្ឋកថា, ថេរគាថាដ្ឋកថា, ថេរីគាថាដ្ឋកថា, វិមានវត្ថុស្ស វិមលវិលាសិនិ នាម អដ្ឋកថា, បេតវត្ថុស្ស វិមលវិលាសិនិ នាម អដ្ឋកថា, វិសុទ្ធិមគ្គស្ស បរមត្ថមញ្ជូសា នាម ដីកា, ទីឃនិកាយស្ស អដ្ឋកថាទីនំ ចតុន្នំ អដ្ឋកថានំ លីនត្ថប្បកាសនិ នាម ដីកា, ជាតកដ្ឋកថាយ លីនត្ថប្បកាសនិ នាម ដីកា, នេត្តិប្ប-ករណដ្ឋកថាយ ដីកា, ពុទ្ធវំសដ្ឋកថាយ បរមត្ថទីបនី នាម ដីកា, អភិធម្មដ្ឋកថាយ ដីកា លីនត្ថវណ្ណនា នាម អនុដីកាតិ ឥមេ ចុទ្ទសមត្តេ

បានរចនាគម្ពីរឈ្មោះ មហាកុរុន្ទិ ។ អាចារ្យឯទៀតបានរចនាអដ្ឋកថានៃគម្ពីរមហាបច្ចរិយ ។ អាចារ្យឯទៀតបានរចនាអដ្ឋកថានៃគម្ពីរកុរុន្ទិ ។ មហាពុទ្ធឃោសាចារ្យបានរចនាគម្ពីរ ១៣ គឺ វិសុទ្ធិមគ្គ ១ អដ្ឋកថាទីឃនិកាយ ឈ្មោះ សុមង្គលវិលាសិនិ ១ អដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះ បបញ្ចសូទនី ១ អដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថប្បកាសិនី ១ អដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី ១ អដ្ឋកថាបញ្ចវិន័យ ឈ្មោះ សមន្តប្បាសាទិកា ១ អដ្ឋកថាអភិធម្ម ៧ គម្ពីរឈ្មោះ បរមត្ថកថា[1] ១ វិសុទ្ធិអដ្ឋកថានៃមាតិកាបាតិមោក្ខ ឈ្មោះ កង្ខាវិតរណី ១ ធម្មបទដ្ឋកថា ១ ជាតកដ្ឋកថា ១ ខុទ្ទកបាឋដ្ឋកថា ១ សុត្តនិបាតដ្ឋកថា ១ អបទានដ្ឋកថា ១ ។ ពុទ្ធទត្តាចារ្យបានរចនាគម្ពីរ ៤ គឺ វិនយវិនិច្ឆ័យ ១ ឧត្តរវិនិច្ឆ័យ ១ អភិធម្មាវតារ ១ អដ្ឋកថាពុទ្ធវំស ឈ្មោះ មធុរត្ថវិលាសិនិ ១ ។ អានន្ទាចារ្យបានរចនាដីកានៃអដ្ឋកថាអភិធម្ម ៧ គម្ពីរឈ្មោះ មូលដីកា ។ ធម្មបាលាចារ្យបានរចនាគម្ពីរ ១៤ គឺ នេត្តិប្បករណដ្ឋកថា ១ ឥតិវុត្តកដ្ឋកថា ១ ឧទានដ្ឋកថា១ ចរិយាបិដកដ្ឋកថា ១ ថេរគាថាដ្ឋកថា ១ ថេរីគាថាដ្ឋកថា ១ អដ្ឋកថាវិមានវត្ថុ ឈ្មោះ វិមលវិលាសិនិ[2] ១ អដ្ឋកថា បេតវត្ថុឈ្មោះ វិមល-វិលាសិនិ[3]១ ដីកាវិសុទ្ធិមគ្គ ឈ្មោះ បរមត្ថមញ្ជូសា ១ ដីកានៃអដ្ឋកថា ទាំង ៤ មានអដ្ឋកថា ទីឃនិកាយជាដើមឈ្មោះ លីនត្ថប្បកាសិនិដីកា ១ ជាតកដ្ឋកថា ឈ្មោះ លីនត្ថប្បកាសិនិ ១ ដីកានៃនេត្តិប្បករណដ្ឋកថា ១

---

១ ច្បាប់ខ្លះថា ឈ្មោះ បរមត្ថទីបនី ។ ២~៣ ច្បាប់ខ្លះថា ឈ្មោះ បរមត្ថទីបនី ដែរ ។

គន្ថេ អកាសិ ។ ទ្វេ បុព្វាចរិយានាមា ចរិយានិរុត្តិមញ្ជូសំ នាម
ចុល្លនិរុត្តិ ដីកញ្ច មហានិរុត្តិសង្ខេបញ្ច អកំសុ ។ មហាវជិរពុទ្ធិនាមា-
ចរិយោ វិនយគណ្ឋិនាម បករណំ អកាសិ ។ ទីបង្ករសង្ខាតោ វិមលពុទ្ធិ-
នាមាចរិយោ មុខមត្តទីបនី នាមកំ ន្យាសប្បករណំ អកាសិ ។ ចុល្លវជិរ-
ពុទ្ធិនាមាចរិយោ អត្ថព្យាខ្យានំ នាម បករណំ អកាសិ ។ ទីបង្ករោ
នាមាចរិយោ រូបសិទ្ធិបករណំ រូបសិទ្ធិដីកំ សម្បបញ្ច សុត្តពេ្ញតិ តិវិធំ
បករណំ អកាសិ ។ អានន្ទាចរិយស្ស ជេដ្ឋសិស្សោ ធម្មបាលោ
នាមាចរិយោ សច្ចសង្ខេបំ នាម បករណំ អកាសិ ។ កស្សបោ
នាមាចរិយោ មោហវិច្ឆេទនី វិមតិច្ឆេទនី ទសពុទ្ធវំសោ អនាគតវំសោតិ
ចតុវិធំ បករណំ អកាសិ ។ មហានាមោ នាមាចរិយោ សទ្ធម្មប្បកាសនី
នាម បដិសម្ភិទាមគ្គស្ស អដ្ឋកថំ អកាសិ ។ ទីបវំសោ ថូបវំសោ ពោធិ-
វំសោ ចូឡវំសោ មហាវំសោ បដិសម្ភិទាមគ្គដ្ឋកថា គណ្ឋិ ចេតិ ឥមេ ឆ
គន្ថា មហានាមាចរិយេន វិសុំ វិសុំ កតា ។ នវោ មហានាមោ នាមាចរិយោ
នវំ មហាវំសំ នាម បករណំ អកាសិ ។ ឧបសេនោ នាមាចរិយោ
សទ្ធម្មប្បជ្ជោតិកំ នាម មហានិទ្ទេសស្ស អដ្ឋកថំ អកាសិ ។ មោគ្គល្លានោ
នាមាចរិយោ មោគ្គល្លានព្យាករណំ នាម បករណំ អកាសិ ។
សង្ឃរក្ខិតោ នាមាចរិយោ សុពោធាលង្ការំ នាម បករណំ អកាសិ ។
វុត្តោទយការោ នាមាចរិយោ វុត្តោទយំ នាម បករណំ អកាសិ ។
ធម្មសិរិ នាមាចរិយោ ខុទ្ទកសិក្ខំ នាម បករណំ អកាសិ ។ បុរាណ-
ខុទ្ទសិក្ខាយ ដីកា មូលសិក្ខាយ ចេតិ ឥមេ ទ្វេ គន្ថា ទ្វេហាចរិយេហិ
វិសុំ វិសុំ កតា ។ អនុរុទ្ធោ នាមាចរិយោ បរមត្ថវិនិច្ឆយំ នាមរូបបរិច្ឆេទំ

ដីកាពុទ្ធវំសដ្ឋកថា ឈ្មោះ បរមត្ថទីបនី ១ អនុដីកានៃអភិធម្មដ្ឋកថាដីកា ឈ្មោះលីនត្ថវណ្ណនា ១ ។

បុញ្ញាចារ្យ២រូប បានរចនាចុល្លនិរុត្តិដីកា ឈ្មោះ ចរិយានិរុត្តិមញ្ជូសា១ មហារុត្តិសង្ខេប ១ ។ មហាវជិរពុទ្ធាចារ្យ បានរចនាបករណ៍ឈ្មោះ វិនយគណ្ឋិ[១] ។ វិមលពុទ្ធាចារ្យ ហៅ ទីបង្ករ បានរចនាន្យាសប្បករណ៍ ឈ្មោះ មុខមត្តទីបនី ។ ចុល្លវជិរពុទ្ធាចារ្យ បានរចនាអត្ថព្យាខ្យានប្បករណ៍ ។ អាចារ្យទីបង្ករបានរចនាបករណ៍ ៣ គឺ រូបសិទ្ធិបករណ៍ ១ រូបសិទ្ធិដីកា ១ សម្បបញ្ចសូត្រ ១ ។ ធម្មបាលាចារ្យជាសិស្សច្បងនៃអានន្ទាចារ្យបានរចនា សច្ចសង្ខេបបករណ៍ ។ កស្សបាចារ្យបានរចនាបករណ៍ ៤ គឺ មោហវិច្ឆេទនី១ វិមតិច្ឆេទនី ១ ទសពុទ្ធវំស ១ អនាគតវំស ១ ។ មហានាមាចារ្យបានរចនា អដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះ សទ្ធម្មប្បកាសិនី ។ មហានាមាចារ្យបាន រចនាគម្ពីរ ៦ ផ្សេងទៀតគឺ ទីបវំស ១ ថូបវំស ១ ពោធិវំស ១ ចូឡវំស ១ មហាវំស ១ បដិសម្ភិទាមគ្គដ្ឋកថាគណ្ឋិ ១ ។ មហានាមាចារ្យថ្មី បានរចនា នវមហាវំសប្បករណ៍ ។ ឧបសេនាចារ្យបានរចនាអដ្ឋកថា មហានិទ្ទេស ឈ្មោះ សទ្ធម្មប្បជ្ជោតិកា ។ មោគ្គល្លានាចារ្យ បានរចនាមោគ្គល្លាន-ព្យាករណបករណ៍ ។ សង្ឃរក្ខិតាចារ្យបានរចនា សុពោធាលង្ការប្បករណ៍ ។ វុត្តោទយការាចារ្យបានរចនាវុត្តោទយបករណ៍ ។ ធម្មសិរាចារ្យបានរចនាខុទ្ទ-

---

[១] គម្ពីរនេះតែងហៅឈ្មោះថា វជិរពុទ្ធិដីកា ។

អភិធម្មត្ថសង្គហំ ចេតិ តិវិធំ បករណំ អកាសិ ។ ខេមោ នាមាចរិយោ ខេមំ នាម បករណំ អកាសិ ។ សារិបុត្តោ នាមាចរិយោ វិនយដ្ឋកថាយ សារត្ថទីបនី នាម ដីកំ វិនយសង្គហប្បករណំ វិនយសង្គហដីកំ អង្គុត្តរដ្ឋកថាយ សារត្ថមញ្ជូសំ នាម នវំ ដីកំ បញ្ចិកា ដីកញ្ចេតិ ឥមេ បញ្ច គន្ថេ អកាសិ ។ ពុទ្ធនាគោ នាមាចរិយោ វិនយត្ថមញ្ជូសំ នាម កង្ខាវិតរណីយា ដីកំ អកាសិ ។ នវោ មោគ្គល្លានោ នាមាចរិយោ អភិធានប្បទីបិកំ នាម បករណំ អកាសិ ។ វាចិស្សរោ នាមាចរិយោ មហាសាមិ នាម សុពោធាលង្ការស្ស ដីកា វុត្តោទយវិវរណំ សុមង្គ-លប្បសាទនិ នាម ខុទ្ទសិក្ខាយ ដីកា សម្ពន្ធចិន្តា សម្ពន្ធចិន្តាយ ដីកា ពាលាវតារោ មោគ្គល្លានព្យាករណស្ស បញ្ចិកាយ ដីកា យោគវិនិច្ឆយោ វិនយវិនិច្ឆយស្ស ដីកា ឧត្តរវិនិច្ឆយស្ស ដីកា នាមរូបបរិច្ឆេទស្ស វិភាគោ សទ្ទត្ថស្ស បទរូបវិភាវនំ ខេមស្ស បករណស្ស ដីកា សីមាលង្ការោ យ ដីកា រូបវិភាគោ បច្ចយសង្គហោ សច្ចសង្ខេបស្ស ដីកា ចេតិ ឥមេ អដ្ឋារស គន្ថេ អកាសិ ។ សុមង្គលោ នាមាចរិយោ អភិធម្មាវតារស្ស ដីកញ្ច អភិធម្មត្ថសង្គហស្ស ដីកញ្ច ទុវិធំ បករណំ អកាសិ ។ ពុទ្ធបិយោ នាមាចរិយោ សារត្ថសង្គហំ នាម បករណំ អកាសិ ។ ធម្មកិត្តិ នាមាចរិយោ ទន្តធាតុប្បករណំ អកាសិ ។ មេធង្ករោ នាមាចរិយោ ជិនចរិតំ នាម បករណំ អកាសិ ។ ពុទ្ធរក្ខិតោ នាមាចរិយោ ជិនលង្ការញ្ច ជិនលង្ការស្ស ដីកញ្ចាតិ ទុវិធំ បករណំ អកាសិ ។ ឧបតិស្សោ នាមាចរិយោ អនាគតវំសស្ស អដ្ឋកថំ អកាសិ ។ កង្ខាវិតរណីយា លីនត្ថប្បកាសិនិ និសន្ទេហោ ធម្មានុសារណី

សិក្ខាបករណ៍ ។ អាចារ្យ ២ រូបបានរចនាគម្ពីរ ២ ដោយឡែកគឺ បុរាណ-ខុទ្ទសិក្ខាដីកា ១ មូលសិក្ខាដីកា ១ ។ អនុរុទ្ធាចារ្យបានរចនាបករណ៍ ៣ គឺ បរមត្ថវិនិច្ឆ័យ ១ នាមរូបបរិច្ឆេទ ១ អភិធម្មត្ថសង្គហៈ ១ ។ ខេមាចារ្យ បានរចនាខេមបករណ៍ ។ សារិបុត្តាចារ្យបានរចនាគម្ពីរ ៥ គឺ ដីកានៃ វិនយដ្ឋកថា ឈ្មោះ សារត្ថទីបនី ១ វិនយសង្គហបករណ៍ ១ វិនយ-សង្គហដីកា ១ នវដីកានៃអង្គុត្តរដ្ឋកថា ឈ្មោះ សារត្ថមញ្ជូសា ១ បញ្ចិកា-ដីកា ១ ។ ពុទ្ធនាគាចារ្យបានរចនាដីកាកង្ខាវិតរណី ឈ្មោះវិនយត្ថមញ្ជូសា ។ នវមោគ្គល្លានាចារ្យបានរចនាអភិធានប្បទីបិកាបករណ៍ ។ វាចិស្សរាចារ្យបាន រចនាគម្ពីរ១៨គឺ សុពោធាលង្ការដីកា ឈ្មោះ មហាសាមិ ១ វុត្តោទយវិវរណៈ ១ ខុទ្ទសិក្ខាដីកា ឈ្មោះ សុមង្គលប្បសាទនិ ១ សម្ពន្ធចិន្តា ១ សម្ពន្ធចិន្តាដីកា ១ ពាលាវតារ ១ បញ្ចិកាដីកានៃគម្ពីរមោគ្គល្លានព្យាករណ៍ ១ យោគវិនិច្ឆ័យ ១ វិនយវិនិច្ឆយដីកា ១ ឧត្តរវិនិច្ឆយដីកា ១ នាមរូបបរិច្ឆេទវិភាគ ១ សទ្ទត្ថ-បទរូបវិភាវនៈ ១ ខេមបករណដីកា ១ សីមាលង្ការៈ ១ មូលសិក្ខាដីកា ១ រូបវិភាគ ១ បច្ចយសង្គហៈ ១ សច្ចសង្ខេបដីកា ១ ។ សុមង្គលាចារ្យ បានរចនាបករណ៍ ២ គឺ អភិធម្មាវតារដីកា ១ អភិធម្មត្ថសង្គហដីកា ១ ។ ពុទ្ធបិយាចារ្យបានរចនា សារត្ថសង្គហបករណ៍ ។ ធម្មកិត្តាចារ្យបានរចនា ទន្តធាតុប្បករណ៍ ។ មេធង្ករាចារ្យបានរចនាជិនចរិតបករណ៍ ។ ពុទ្ធរក្ខិតាចារ្យ បានរចនាបករណ៍ ២ គឺ ជិនលង្ការៈ ១ ជិនលង្ការដីកា ១ ។ ឧបតិស្សាចារ្យ

ញេយ្យាសន្តតិ ញេយ្យាសន្តតិយា ដីកា សុមតាទាវតារោ លោកប្បញ្ញត្តិ-
ប្បករណំ តថាគតុប្បត្តិបករណំ នលាដធាតុវណ្ណនា សីហឡវត្ថុ
ធម្មទីបកោ បដិបត្តិសង្គហោ វិសុទ្ធិមគ្គណ្ឋិ អភិធម្មគណ្ឋិ នេត្តិប្បករណ-
គណ្ឋិ វិសុទ្ធិមគ្គចូឡនវដីកា សោតព្វមាលិនី បសាទជននី ឱកាស-
លោកោ សុពោធាលង្ការស្ស នវ ដីកា ចេតិ ឥមេ វីសតិ គន្ថា
វីសតាចរិយេហិ វិសុំ វិសុំ កតា ។ សទ្ធម្មសិរិ នាមាចរិយោ
សទ្ទត្ថភេទចិន្តា នាម បករណំ អកាសិ ។ ទេវោ នាមាចរិយោ សុមន-
កូដវណ្ណនំ នាម បករណំ អកាសិ ។ ចុល្លពុទ្ធឃោសោ នាមាចរិយោ
សោតត្ថកិនិទានំ នាម បករណំ អកាសិ ។ រដ្ឋបាលោ នាមាចរិយោ
មធុរសង្គាហណីកិត្តិ នាម បករណំ អកាសិ ។ សុភូតចន្ទោ នាមាចរិយោ
លិង្គត្ថវិវរណប្បករណំ អកាសិ ។ អគ្គវំសោ នាមាចរិយោ សទ្ទនីតិ
បករណំ នាម អកាសិ ។ វជិរពុទ្ធិ នាមាចរិយោ មហាដីកំ នាម
ន្យាសបករណដីកំ អកាសិ ។ គុណសាគរោ នាមាចរិយោ មុខមត្តសារំ
មុខមត្តសារស្ស ដីកញ្ច ទុវិធំ បករណំ អកាសិ ។ អភយោ នាមាចរិយោ
សទ្ទត្ថភេទចិន្តាយ មហាដីកំ អកាសិ ។ ញាណសាគរោ នាមាចរិយោ
លិង្គត្ថវិវរណប្បកាសនំ នាម បករណំ អកាសិ ។ អញ្ញតរោ អាចរិយោ
គុឡ្ហត្ថដីកញ្ច ពាលប្បពោធនញ្ច ទុវិធំ បករណំ អកាសិ ។ អញ្ញតរោ
អាចរិយោ សទ្ទត្ថភេទចិន្តាយ មជ្ឈិមដីកំ អកាសិ ។ ឧត្តមោ
នាមាចរិយោ ពាលាវតារដីកញ្ច លិង្គត្ថវិវរណដីកញ្ច ទុវិធំ បករណំ
អកាសិ ។ អញ្ញតរោ អាចរិយោ សទ្ទត្ថភេទចិន្តាយ នវដីកំ អកាសិ ។
ឯកោ អមច្ចោ អភិធានប្បទីបិកាយ ដីកញ្ច គណ្ឋិបករណស្ស ទណ្ឌីប្បករណស្ស

បានរចនា អដ្ឋកថាអនាគតវំស ។ អាចារ្យ២០រូបបានរចនាគម្ពីរ២០ផ្សេងៗគ្នាគឺ លីនត្ថប្បកាសិនិនៃកង្ខាវិតរណី[១] ១ និសន្ទេហ ១ ធម្មានុសារណី ញេយ្យា-សន្តតិ ១ ញេយ្យាសន្តតិដីកា ១ សុមតាវតារ ១ លោកប្បញ្ញត្តិបករណ៍ តថាគតុប្បត្តិបករណ៍ ១ នលាដធាតុវណ្ណនា ១ សីហឡវត្ថុ ១ ធម្មទីបកៈ១ បដិបត្តិសង្គហៈ ១ វិសុទ្ធិមគ្គគណ្ឋិ ១ អភិធម្មគណ្ឋិ១ នេត្តិប្បករណគណ្ឋិ ១ វិសុទ្ធិមគ្គចូឡនវដីកា ១ សោតព្វមាលិនី ១ បសាទជននី ១ ឱកស្សលោក ១ សុពោធាលង្ការនវដីកា ។ សទ្ធម្មសិរាចារ្យបានរចនា សទ្ទត្ថភេទចិន្តប្បករណ៍ ។ ទេវាចារ្យបានរចនា សុមនកូដវណ្ណនាបករណ៍ ។ ចុល្លពុទ្ធឃោសាចារ្យ បានរចនាសោតត្តកិនិទានបករណ៍ ។ វដ្ឋបាលាចារ្យបានរចនាមធុរសង្គហណីកិត្តិ-បករណ៍ ។ សុភូតចន្ទាចារ្យបានរចនា លិង្គត្ថវិវរណបករណ៍ ។ អគ្គវំសាចារ្យ បានរចនា សទ្ទនីតិបករណ៍ ។ វជិរពុទ្ធាចារ្យបានរចនាឡាសបករណដីកា ឈ្មោះ មហាដីកា ។ គុណសាគរាចារ្យបានរចនាបករណ៍គឺ មុខមត្តសារៈ ១ មុខមត្តសារដីកា ១ ។ អភយាចារ្យបានរចនាមហាដីកានៃសទ្ទត្ថភេទចិន្តា ។ ញាណសាគរាចារ្យបានរចនា លិង្គត្ថវិវរណប្បកាសនបករណ៍ ។ អាចារ្យឯទៀត បានរចនាបករណ៍ ២ គឺ គូឡ្ហត្ថដីកា ១ ពាលប្បពោធនៈ ១ ។ អាចារ្យឯទៀត បានរចនា មជ្ឈិមដីកានៃសទ្ទត្ថភេទចិន្តា ។ ឧត្តមាចារ្យបានរចនាបករណ៍២គឺ ពាលាវតារដីកា ១ លិង្គត្ថវិវរណដីកា ១ ។ អាចារ្យឯទៀត បានរចនានវដីកា

[១] តែងធ្លាប់ហៅគម្ពីរនេះថា កង្ខាវិតរណីបុរាណដីកា ។

មាគធភូតំ ដីកញ្ច កោលទ្ធជនស្ស សកជភាសាយ កតដីកញ្ច តិវិធំ បករណំ អកាសិ ។ ធម្មសេនាបតិ នាមាចរិយោ ការិកំ, ឯតិមាសបិទីបនិ, មនោហារញ្ច តិវិធំ បករណំ អកាសិ ។ អញ្ញតរោ អាចរិយោ ការិកាយ ដីកំ អកាសិ ។ អញ្ញតរោ អាចរិយោ ឯតិមាសបិទីបិកាយ ដីកំ អកាសិ ។

អញ្ញតរោ អាចរិយោ សទ្ទពិន្ទុ នាម បករណំ អកាសិ ។ សទ្ធម្មគុរុ នាមាចរិយោ សទ្ទវុត្តិប្បកាសកំ នាម បករណំ អកាសិ ។ សារិបុត្តោ នាមាចរិយោ សទ្ទវុត្តិប្បកាសកស្ស ដីកំ អកាសិ ។ អញ្ញតរោ អាចរិយោ កច្ចាយនសារំ នាម បករណំ កច្ចាយនសារស្ស ដីកញ្ច ទុវិធំ បករណំ អកាសិ ។ នវោ មេធង្ករោ នាមាចរិយោ លោកទីបកសារំ នាម បករណំ អកាសិ ។ អគ្គបណ្ឌិតោ នាមាចរិយោ លោកុប្បត្តិ នាម បករណំ អកាសិ ។ ចីវរោ នាមាចរិយោ ជង្ឃទាសកស្ស ដីកំ អកាសិ ។ មាតិកត្ថទីបនី អភិធម្មត្ថសង្គហវណ្ណនា សីមាលង្ការស្ស ដីកា វិនយសមុដ្ឋានទីបនី ដីកា គណ្ឋិសារោ បដ្ឋានគណនា នយោ សុត្តនិទ្ទេសោ បាតិមោក្ខោ ចេតិ ឥមេ អដ្ឋ គន្ថេ សទ្ធម្មជោតិបាលាចរិយោ អកាសិ ។ វិមលពុទ្ធិ នាមាចរិយោ អភិធម្មបន្នរសដ្ឋានំ នាម បករណំ អកាសិ ។ នវោ វិមលពុទ្ធិ នាមាចរិយោ សទ្ទសារត្ថជាលិនី សទ្ទសារត្ថជាលិនិយា ដីកា វុត្តោទយដីកា បរមត្ថមញ្ជូសា នាម អភិធម្មសង្គហដីកាយ អនុដីកា ទសគណ្ឋិវណ្ណនា មាគធភូតាវិទគ្គមុខមណ្ឌនដីកា ចេតិ ឥមេ ឆ គន្ថេ អកាសិ ។ អញ្ញតរោ អាចរិយោ បញ្ចប្បករណដីកាយ នវានុដីកំ

នៃសទ្ទត្ថភេទចិន្តា ។ អាមាត្យម្នាក់បានរចនាបករណ៍៣គឺ អភិធានប្បទីបិកា-ដីកា ១ គណ្ឋិបករណទណ្ឌីបករណមាគធភូតដីកា ១ កោលទ្ធជនសកដ-ភាសាគតដីកា ១ ។ ធម្មសេនាបតាចារ្យបានរចនាបករណ៍ ៣ គឺ ការិកៈ ១ ឯតិមាសបិទីបនី ១ មនោហារៈ ១ ។ អាចារឯទៀតបានរចនាការិកាដីកា ។ អាចារ្យឯទៀតបានរចនា ឯតិមាសបិទីបនីដីកា ។

អាចារ្យឯទៀតបានរចនា សទ្ទពិន្ទុបករណ៍ ។ សទ្ធម្មគុរាចារ្យបានរចនា សទ្ទវុត្តិប្បកាសកប្បករណ៍ ។ សារិបុត្តាចារ្យ បានរចនាសទ្ទវុត្តិប្បកាសកដីកា ។ អាចារ្យឯទៀតបានរចនាបករណ៍ ២ គឺ កច្ចាយនសារប្បករណ៍ ១ កច្ចាយនសារដីកា ។ នវមេធង្ករាចារ្យបានរចនា លោកទីបកសារបករណ៍ ។ អគ្គបណ្ឌិតាចារ្យបានរចនា លោកុប្បត្តិបករណ៍ ។ ចីវរាចារ្យបានរចនា ជង្ឃទាសកដីកា ។ សទ្ធម្មជោតិបាលាចារ្យបានរចនាគម្ពីរ៨គឺ មាតិកត្ថទីបនី១ អភិធម្មត្ថសង្គហវណ្ណនា ១ សីមាលង្ការដីកា ១ វិនយសមុដ្ឋានទីបនីដីកា ១ គណ្ឋិសារៈ ១ បដ្ឋានគណនានយៈ ១ សុត្តនិទ្ទេស ១ បាតិមោក្ខ ១ ។ វិមលពុទ្ធាចារ្យបានរចនា អភិធម្មបន្នរសដ្ឋានបករណ៍ ។ នវវិមលពុទ្ធាចារ្យ បានរចនាគម្ពីរ ៦ គឺ សទ្ទសារត្ថជាលិនី ១ សទ្ទសារត្ថជាលិនីដីកា ១ វុត្តោទយដីកា ១ បរមត្ថមញ្ជូសានុដីកានៃអភិធម្មត្ថសង្គហដីកា ១ ទស-គណ្ឋិវណ្ណនា ១ មាគធភូតាវិទគ្គមុខមណ្ឌនដីកា ១ ។ អាចារ្យឯទៀត បានរចនានវានុដីកានៃបញ្ចប្បករណដីកា ។ អរិយវំសាចារ្យបានរចនា មណិ-

អកាសិ ។ អរិយវំសោ នាមាចរិយោ អភិធម្មត្ថសង្គហដីកាយ (បរមត្ថ) មណិសារមញ្ជូសំ នាម នវានុដីកំ អកាសិ ។ អភិធម្មត្ថសង្គហស្ស ដីកា បេដកោបទេសស្ស ដីកា ចតុភាណវារស្ស អដ្ឋកថា មហាសារប្បកាសនី មហាទីបនី សារត្ថទីបនីគតិប្បករណំ ហត្ថសារោ កុម្មសង្គហោ កុម្មនិទ្ទេសោ ទសវត្ថុកាយវិរតិដីកា ជោតនានិរុត្តិ វិភត្តិកថា កច្ចាយ-នវិវរណា សទ្ធម្មមាលិនី បញ្ចគតិវណ្ណនា ពាលចិត្តបពោធនំ ធម្មចក្ក-សុត្តស្ស នវដ្ឋកថា ទន្តធាតុប្បករណស្ស ដីកា ចេតិ ឥមេ វីសតិ គន្ថា នានាចរិយេហិ កតា ។ អញ្ញានិ បន បករណានិ អត្ថិ ?។

កតមានិ សទ្ធម្មោ បាយនោ, ពាលប្បពោធនបករណស្ស ដីកា ច ជិនាលង្ការប្បករណស្ស នវដីកា ច លិង្គត្ថវិវរណំ លិង្គវិនិច្ឆយោ បាតិមោក្ខវិវរណំ បរមត្ថកថាវិវរណំ សមន្តប្បាសាទិកាវិវរណំ ចតុ-ភាណវារដ្ឋកថាវិវរណំ អភិធម្មត្ថសង្គហវិវរណំ សច្ចសង្ខេបវិវរណំ សទ្ទត្ថភេទចិន្តាវិវរណំ សទ្ទវុត្តិវិវរណំ កច្ចាយនសារវិវរណំ អភិធម្មត្ថ-សង្គហស្ស ដីកា វិវរណំ មហាវេស្សន្តរាជាតកស្ស វិវរណំ សក្កាភិមតំ មហាវេស្សន្តរជាតកស្ស នវដ្ឋកថា បឋមសម្ពោធិ លោកនេត្តិ ច ពុទ្ធឃោសាចរិយនិទានំ មិលិន្ទប្បញ្ហាវណ្ណនា ចតុរារក្ខា, ចតុរក្ខាយ អដ្ឋកថា សទ្ទវុត្តិប្បករណស្ស នវដីកា ឥច្ចេវំ បញ្ចវីសតិ បមាណានិ បករណានិ លង្កាទីបាទីសុដ្ឋានេសុ បណ្ឌិតេហិ កតានិ អហេសុំ សម្ពុទ្ធេគាថា ច នរទេវ នាម គាថា ច ទាតវេ ចីរត្តិ គាថា ច វីសតិ

សារមញ្ជូសានវានុដីកានៃអភិធម្មត្ថសង្គហដីកា ។ អាចារ្យឯទៀតៗ បានរចនាគម្ពីរ ២០ គឺ អភិធម្មត្ថសង្គហដីកា ១ បេដកោបទេសដីកា ១ ចតុភាណវារដ្ឋកថា ១ មហាសារប្បកាសិនី ១ មហាទីបនី ១ សារត្ថ-ទីបនីគតិប្បករណ៍ ១ ហត្ថសារៈ ១ កុម្មសង្គហៈ ១ កុម្មនិទ្ទេស ១ ទសវត្ថុកាយវិរតិដីកា ១ ជោតនានិរុត្តិ ១ វិភត្តិកថា ១ កច្ចាយនវិវរណ ១ សទ្ទម្មមាលិនី ១ បញ្ចគតិវណ្ណនា ១ ពាលចិត្តបពោធនៈ ១ ធម្មចក្កសុត្ត-នវដ្ឋកថា ១ ទន្តធាតុប្បករណដីកា ១ ។

តើបករណ៍ទាំងឡាយដទៃមានគម្ពីរអ្វីខ្លះ? ។ សទ្ទម្មបាយនៈ១ ពាលប្ប-ពោធនបករណដីកា ១ ជិនាលង្ការប្បករណនវដីកា ១ លិង្គវិវរណៈ ១ លិង្គវិនិច្ឆ័យ ១ បាតិមោក្ខវិវរណៈ ១ បរមត្ថកថាវិវរណៈ១ សមន្តប្បាសាទិកា-វិវរណៈ ១ ចតុភាណវារដ្ឋកថាវិវរណៈ ១ អភិធម្មត្ថសង្គហវិវរណៈ ១ សច្ច-សង្ខេបវិវរណៈ ១ សទ្ទត្ថភេទចិន្តាវិវរណៈ ១ សទ្ទវុត្តិវិវរណៈ១ កច្ចាយន-សារវិវរណៈ ១ អភិធម្មត្ថសង្គហដីកាវិវរណៈ ១ មហាវេស្សន្តរជាតកវិវរណៈ១ សក្កភិមតៈ ១ មហាវេស្សន្តរជាតកនវដ្ឋកថា ១ បឋមសម្ពោធិ ១ លោកនេត្តិ ១ ពុទ្ធឃោសាចរិយនិទាន ១ មិលិន្ទប្បញ្ហាវណ្ណនា ១ ចតុរារក្ខា ១ ចតុរារក្ខាដ្ឋកថា ១ សទ្ទវុត្តិប្បករណនវដីកា ១ រួមបករណ៍ទាំង ២៥ នេះ បណ្ឌិតទាំងឡាយបានរចនាក្នុងលង្កាទ្វីបជាដើម បណ្ឌិតបានរចនាគាថាទាំងឡាយមាន ពុទ្ធប្បណាមគាថាជាដើមក្នុងលង្កាទ្វីបគឺ សម្ពុទ្ធគាថា ១ នរ-

ឱវាទគាថា ច ទានសត្តិ សីលសត្តិ សប្បាទានវណ្ណនា អនន្តពុទ្ធវន្ទនគាថា ច អដ្ឋវីសតិ ពុទ្ធវន្ទនគាថា ច អតីតានាគតបច្ចុប្បន្នវន្ទនគាថា ច អសីតិមហាសាវកវន្ទនគាថា ច នវហារគុណវណ្ណនា ចាតិ ឥមេ ពុទ្ធបណាមគាថាទិកា គាថាយោ បណ្ឌិតេហិ លង្កាទីបាទិសុដ្ឋានេសុ កតា អហេសុំ (ឥតិ ចុល្លគន្ថវំសេ គន្ថការកាចរិយទីបកោ នាម ទុតិយោ បរិច្ឆេទោ) ។

## ៣.អាចរិយានំ សញ្ញាតដ្ឋានប្បរិច្ឆេទោ

អាចរិយេសុ ច អត្ថិ ជម្ពុទីបិកាចរិយា អត្ថិ, លង្កាទីបិកាចរិយា ។ កតមេ ជម្ពុទីបិកាចរិយា ? ។ កតមេ លង្កាទីបិកាចរិយា ? ។ មហាកច្ចាយនោ ជម្ពុទីបិកាចរិយោ សោ ហិ អវន្តិរដ្ឋេ ឧជ្ជេនី នគរេ ចន្ទប្បជ្ជោតស្ស នាម រញ្ញោ បុរោហិតោ ហុត្វា កាមានំ អាទីនវំ ទិស្វា, ឃរាវាសំ បហាយ សត្ថុសាសនេ បព្វជិត្វា ហេដ្ឋា វុត្តប្បការេ គន្ថេ អកាសិ ។ មហាអដ្ឋកថាចរិយោ ជម្ពុទីបិកោ ។ មហាបច្ចរិកាចរិយោ, មហាកុរុន្ទិកាចរិយោ, អញ្ញតរោ អាចរិយា ទ្វេតិ ឥមេ ច ភូវាចរិយា លង្កាទីបិកាចរិយា នាម ។ តេ កិរ ពុទ្ធឃោសាចរិយស្ស បុរេ ភូតាចរិយេ កាលេ អហេសុំ ។ មហាពុទ្ធឃោសាចរិយោ ជម្ពុទីបិកោ ។ សោ កិរ មគធរដ្ឋេ ឃោសកគាមេ រញ្ញោ បុរោហិតស្ស កេសិ នាម ព្រាហ្មណស្ស បុត្តោ, សត្ថុសាសនេ បព្វជិត្វា លង្កាទីបំ គតោ ហេដ្ឋា វុត្តប្បការេ គន្ថេ អកាសិ ។

ទេវគាថា ១ ទាតផបីរត្តិគាថា១ វីសតិឱវាទគាថា ១ ទានសត្តិ ១ សីលសត្តិ ១ សប្បទានវណ្ណនា ១ អនន្តពុទ្ធវន្ទនគាថា ១ អដ្ឋវីសតិពុទ្ធវន្ទនគាថា ១ អតីតានាគតបច្ចុប្បន្នវន្ទនគាថា ១ អសីតិមហាសាវកវន្ទនគាថា ១ នវហារៈ-គុណវណ្ណនា ១ ។

(បរិច្ឆេទទី២រៀបរាប់អាចារ្យអ្នករចនាគម្ពីរក្នុងចុល្លគន្ថវំសចប់តែប៉ុណ្ណេះ ) ។

## ៣.បរិច្ឆេទរៀបរាប់ទីកំណើតរបស់អាចារ្យ

បណ្តាអាចារ្យទាំងនោះ អាចារ្យក្នុងជម្ពូទ្វីប[១]ក៏មាន ក្នុងលង្កាទ្វីប[២]ក៏មាន ។ តើព្រះថេរៈអង្គណាខ្លះ ជាអាចារ្យក្នុងជម្ពូទ្វីប? ។ តើព្រះថេរៈអង្គណាខ្លះ ជាអាចារ្យក្នុងលង្កាទ្វីប ? ។ មហាកច្ចាយនៈជាអាចារ្យក្នុងជម្ពូទ្វីប លោកជាបុរោហិតរបស់ព្រះបាទចណ្ឌប្បជោត ក្នុងឧជ្ជេនីនគរ នាដែនអវន្តិ ឃើញទោសនៃកាមទាំងឡាយហើយ លះបង់ឃរាវាស បួសក្នុងពុទ្ធសាសនា បានរចនាគម្ពីរតាមដែលខ្ញុំពោលហើយខាងដើម ។ មហាអដ្ឋកថាចារ្យជាអាចារ្យជម្ពូទ្វីប ។ មហាបច្ចរិកាចារ្យ មហាកុរុន្ទិកាចារ្យ និងអាចារ្យពីរទៀត ទាំងនេះឈ្មោះភូវាចារ្យ ជាអាចារ្យក្នុលង្កាទ្វីប ។ បានឮថា ពួកលោកកើតក្នុងកាលមុនព្រះពុទ្ធឃោសាចារ្យ ។ មហាពុទ្ធឃោសាចារ្យជាអ្នកជម្ពូទ្វីប។ ឮថា លោកជាកូនរបស់កេសិព្រាហ្មណ៏ ដែលជាបុរោហិតរបស់ព្រះរាជាក្នុងឃោសកគ្រាមនាដែនមគធៈ បានបួសក្នុងសាសនានៃព្រះសាស្តាហើយនិមន្តទៅកាន់កោះលង្កាទ្វីបបានរចនាគម្ពីរតាមដែលខ្ញុំពោលមកហើយខាងដើម ។

---

១ ប្រទេសឥណ្ឌា ២ ប្រទេសស្រីលង្កា ។

ពុទ្ធទត្តាចរិយោ អានន្ទាចរិយោ ធម្មបាលាចរិយោ ទ្វេ បុព្វាចរិយោ មហាវជិរពុទ្ធាចរិយោ ចុល្លវជិរពុទ្ធាចរិយោ វិមលពុទ្ធសង្ខាតោ ទីបង្ករា- ចរិយោ ចុល្លទីបង្ករាចរិយោ ចុល្លធម្មបាលាចរិយោ កស្សបាចរិយោតិ ឥមេ ឯកាទសចរិយា ជម្ពុទីបិកា ហេដ្ឋា វុត្តប្បការេ គន្ថេ អកំសុ ។ មហានាមាចរិយោ អញ្ញតរាចរិយា ចុល្លមហានាមាចរិយោ ឧបសេនា- ចរិយោ មោគ្គល្លានាចរិយោ សង្ឃរក្ខិតាចរិយោ វុត្តោទយការាចរិយោ ធម្មសិរាចរិយោ អញ្ញតរា ទ្វាចរិយា អនុរុទ្ធាចរិយោ ខេមាចរិយោ សារិបុត្តាចរិយោ ពុទ្ធនាគាចរិយោ ចុល្លមោគ្គល្លានាចរិយោ វាចិស្សរ- រាចរិយោ សុមង្គលាចរិយោ ពុទ្ធបិយាចរិយោ ធម្មកិត្តាចរិយោ មេធង្ករាចរិយោ ពុទ្ធរក្ខិតាចរិយោ ឧបតិស្សាចរិយោ អញ្ញតរា វីសតាចរិយា សទ្ធម្មសិរាចរិយោ ទេវាចរិយោ ចុល្លពុទ្ធឃោសាចរិយោ រដ្ឋបាលាចរិយោតិ ឥមេ ទ្វេ បញ្ញាសាចរិយា លង្កាទីបិកាចរិយា នាម ។ សុភូតចន្ទាចរិយោ អគ្គវំសាចរិយោ នវោ វជិរពុទ្ធាចរិយោ គុណសាគរាចរិយោ អភយាចរិយោ ញាណសាគរាចរិយោ អញ្ញតរា ទ្វាចរិយា ឧត្តមាចរិយោ អញ្ញតរោ អាចរិយោ អញ្ញតរោ មហាមច្ចោ ធម្មសេនាបតាចរិយោ អញ្ញតរា តយោ អាចរិយា សទ្ធម្មគុរុ អាចរិយោ សារិបុត្តាចរិយោ អញ្ញតរោ ឯកា អាចរិយោ មេធង្ករាចរិយោ អគ្គបណ្ឌិតាចរិយោ ចីវរាចរិយោ សទ្ធម្មជោតិបាលាចរិយោ វិមលពុទ្ធាចរិយោតិ ឥមេ តេវីសតិ អាចរិយា ជម្ពុទីបិកា ហេដ្ឋា វុត្តប្បការេ គន្ថេ បុក្កាមសង្ខាតេ អរិមទ្ទនគរេ អកំសុ ។

ពុទ្ធទត្តាចារ្យ អានន្ទាចារ្យ ធម្មបាលាចារ្យ ទេ្វបុព្វាចារ្យ មហា-វជិរពុទ្ធាចារ្យ ចុល្លវជិរពុទ្ធាចារ្យ ទីបង្ករាចារ្យ ហៅ វិមលពុទ្ធាចារ្យ ចុល្ល-ទីបង្ករាចារ្យ ចុល្លធម្មបាលាចារ្យ កស្សបាចារ្យ រួមអាចារ្យទាំង ១១ រូបនេះ ជាអ្នកជម្ពូទ្វីប បានរចនាគម្ពីរដូចខ្ញុំពោលមកហើយខាងដើម ។ មហា-នាមាចារ្យ អញ្ញតរាចារ្យ ចុល្លមហានាមាចារ្យ ឧបសេនាចារ្យ មោគ្គល្លា-នាចារ្យ សង្ឃរក្ខិតាចារ្យ វុត្តោទយការាចារ្យ ធម្មសិរាចារ្យ អាចារ្យពីររូបផ្សេង ទៀត អនុរុទ្ធាចារ្យ ខេមាចារ្យ សារិបុត្តាចារ្យ ពុទ្ធនាគាចារ្យ ចុល្លមោគ្គល្លានាចារ្យ វាចិស្សរាចារ្យ សុមង្គលាចារ្យ ពុទ្ធបិយាចារ្យ ធម្មកិត្តាចារ្យ មេធង្ករាចារ្យ ពុទ្ធរក្ខិតាចារ្យ ឧបតិស្សាចារ្យ អញ្ញតរីសតាចារ្យ សទ្ធម្មសិរាចារ្យ ទេវាចារ្យ ចុល្លពុទ្ធឃោសាចារ្យ រដ្ឋបាលាចារ្យ រួមអាចារ្យទាំង ៥២[១] នេះ សុទ្ធតែជាអាចារ្យក្នុងលង្កាទ្វីប ។ សុភូតចន្ទាចារ្យ អគ្គវំសាចារ្យ នវវជិរពុទ្ធចារ្យ គុណសាគរាចារ្យ អភយាចារ្យ ញាណសាគរាចារ្យ អញ្ញទ្វាចារ្យ ឧត្តមាចារ្យ អាចារ្យពីររូប មហាមាត្យឯទៀត ធម្មសេនា-បតាចារ្យ អាចារ្យ ៣ រូបផ្សេងទៀត សទ្ធម្មគុរាចារ្យ សារិបុត្តាចារ្យ អញ្ញតរា-ចារ្យ មេធង្ករាចារ្យ អគ្គបណ្ឌិតាចារ្យ ចីវរាចារ្យ សទ្ធម្មជោតិបាលាចារ្យ វិមលពុទ្ធាចារ្យរួមអាចារ្យទាំង ២៣ នេះ ជាអ្នកជម្ពូទ្វីប បានរចនាគម្ពីរដូច ដែលខ្ញុំពោលហើយខាងដើមក្នុងអរិមទ្ទននគរហៅប្រទេសភូមា( សព្វថ្ងៃ ) ។

១ បាលីថា ទេ្វ បញ្ញាសាចរិយា ប្រែថា អាចារ្យ ៥២ រូប តែរាប់ទៅឃើញតែត្រឹម ៤៦ រូប សូមពិនិត្យមើលផង ។

នវោ វិមលពុទ្ធាចរិយោ ជម្ពុទីបិកោ ហេដ្ឋា វុត្តប្បការេ គន្ថេ បំយនគរេ អកាសិ ។ អញ្ញតរាចរិយោ អរិយវំសាចរិយោតិ ឥមេ ទ្វាចរិយា ជម្ពុទីបិកា ហេដ្ឋា វុត្តប្បការេ គន្ថេ អតិ (នវិ) បុរេ អកំសុ, អញ្ញតរា វីសតាចរិយា ជម្ពុទីបិកា ហេដ្ឋា វុត្តប្បការេ គន្ថេ កិញ្ចិ-បុរាទិយេរេ អកំសុ ។

(ឥតិ ចុល្លគន្ថវំសេ អាចរិយានំ សញ្ញាតដ្ឋានទីបកោ នាម តតិយោ បរិច្ឆេទោ ) ។

## ៤.អាយាយកាចរិយប្បរិច្ឆេទោ

គន្ថា បន សិយា អាយាចនេន អាចរិយេហិ កតា, សិយា អនាយាចនេន អាចរិយេហិ កតា ។ កតមេ គន្ថា អាយាចនេន, កតមេ អនាយាចនេន កតា ? ។ មហាកច្ចាយនគន្ថោ, មហាអដ្ឋកថាគន្ថោ មហាបច្ចរិយគន្ថោ មហាកុរុន្ទិគន្ថោ មហាបច្ចរិយគន្ថស្ស អដ្ឋកថាគន្ថោ មហាកុរុន្ទិគន្ថស្ស អដ្ឋកថា គន្ថោតិ ឥមេហិ ឆ គន្ថេហិ អត្តនោ មតិយា សាសនុគ្គហនត្ថាយ សទ្ធម្មដ្ឋិតិយា កតា ។

## ក.ពុទ្ធឃោសាចរិយគន្ថទីបនា

ពុទ្ធឃោសាចរិយគន្ថេសុ បន វិសុទ្ធិមគ្គោ, សង្ឃបាលេន នាម សង្ឃត្ថេរេន អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ ទីឃនិកាយស្ស

វិមលពុទ្ធាចារ្យអ្នកជម្លូទ៌បបានរចនាគម្ពីរ ដូចខ្ញុំពោលហើយខាងដើម ក្នុងបំយនគរ ។ អាចារ្យពីររូបគឺ អញ្ញតរាចារ្យ ១ អរិយវំសាចារ្យ ១ ជាអ្នកជម្លូទ៌បបានរចនាគម្ពីរដូចខ្ញុំពោលមកហើយខាងដើម ក្នុងអតិបុរីឬនវិបុរី[១] ។ អាចារ្យ ២០ រូបផ្សេងទៀតបានរចនាគម្ពីរដូចខ្ញុំពោលមកហើយខាងដើម ក្នុងផ្ទះមានកិញ្ចិបុរីជាដើម ។

(បរិច្ឆេទទី ៣ រៀបរាប់ទីកំណើតរបស់អាចារ្យក្នុងចុល្លគន្ថវំសចប់ ) ។

## ៤.បរិច្ឆេទរៀបរាប់អាចារ្យមានអ្នកអារាធនានិងមិនមានអ្នកអារាធនា

អាចារ្យទាំងឡាយរចនាគម្ពីរដោយមានអ្នកអារាធនាក៏មាន មិនមានអ្នកអារាធនាក៏មាន ។ គម្ពីរអ្វីខ្លះដែលអាចារ្យរចនាដោយមានអ្នកអារាធនា, គម្ពីរអ្វីខ្លះ ដែលអាចារ្យរចនាដោយមិនមានអ្នកអារាធនា ។ គម្ពីរមហា-កច្ចាយនៈ មហាអដ្ឋកថា មហាបច្ចរិយ មហាកុរុន្ទី មហាបច្ចរិយដ្ឋកថា មហាកុរុន្ទិដ្ឋកថា រួមគម្ពីរទាំង ៦ នេះ រចនាដោយអត្តនោម័តិ[២] ដើម្បីអនុគ្រោះសាសនា និងដើម្បីតាំងនៅនៃព្រះសទ្ធម្ម ។

## ក.បំភ្លឺគម្ពីរដែលព្រះពុទ្ធឃោសាចារ្យរចនាឡើង

បណ្ដាគម្ពីររបស់ពុទ្ធឃោសាចារ្យទាំងអស់ វិសុទ្ធិមគ្គ ពុទ្ធឃោសាចារ្យបានរចនាឡើងដោយការអារាធនារបស់ព្រះសង្ឃត្ថេរព្រះនាម សង្ឃបាល ។

---

១ អតិបុរីឬនវិបុរី សព្វថ្ងៃបានដល់ ក្រុងចៀងហ្មៃ ។ ២ អត្តនោម័តិក្នុងទីនេះ សំដៅដល់ការសង្គាយនាឡើង ឬការរចនាដោយមិនមានអ្នកអារាធនា, សូម្បីអត្តនោម័តិខាងមុខទៀត ក៏មានន័យដូចគ្នា ។

អដ្ឋកថាគន្ថោ ទាឋានាមេន សង្ឃត្ថេរេន អាយាចិតេន ពុទ្ធឃោសា-ចរិយេន កតោ ។ មជ្ឈិមនិកាយស្ស អដ្ឋកថាគន្ថោ ពុទ្ធមិត្តនាមេន ថេរេន អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ សំយុត្តនិកាយស្ស អដ្ឋកថា គន្ថោ ជោតិបាលេន នាម ថេរេន អាយាចិតេន ពុទ្ធឃោ-សាចរិយេន កតោ ។ អង្គុត្តរនិកាយស្ស អដ្ឋកថា គន្ថោ ភទ្ទន្តា នាម ថេរេន សហអាជីវកេន ឧបាសកេន ច អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ សមន្តប្បាសាទិកា នាម អដ្ឋកថាគន្ថោ ពុទ្ធសិរិ នាមេន ថេរេន អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ សត្តន្នំ អភិធម្ម-គន្ថានំ អដ្ឋកថាគន្ថោ ចុល្លពុទ្ធឃោសេន ភិក្ខុនា អាយាចិតេន ពុទ្ធ-ឃោសាចរិយេន កតោ ។ ធម្មបទស្ស អដ្ឋកថាគន្ថោ កុមារកស្សបនាមេន ថេរេន អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ ជាតកស្ស អដ្ឋកថា-គន្ថោ អត្ថទស្សីពុទ្ធមិត្តពុទ្ធបិយទេវសង្ខាតេហិ តីហិ ថេរេហិ អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។ ខុទ្ទកបាឋស្ស អដ្ឋកថាគន្ថោ សុត្តនិបាតស្ស អដ្ឋកថាគន្ថោ អត្តនោ មតិយា ពុទ្ធឃោសាចរិយេន កតោ ។ អបទានស្ស អដ្ឋកថាគន្ថោ បញ្ចនិកាយវិញ្ញូហិ បញ្ចហិ ថេរេហិ អាយាចិតេន ពុទ្ធឃោសាចរិយេន កតោ ។

ពុទ្ធឃោសាចរិយគន្ថទីបនា និដ្ឋិតា ។

